**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៨២...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិដើម្បីប្រជាជន និងការអភិវឌ្ឍន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៨០១ / ២៧៩ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដើម្បីប្រជាជន និងការអភិវឌ្ឍន៍
- យោងតាមសំណើរបស់គណៈកម្មាធិការជាតិដើម្បីប្រជាជន និងការអភិវឌ្ឍន៍

## ស ំ រេ ច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១** : អនុក្រឹត្យនេះកំណត់ពីបេសកកម្ម មុខងារ ភារកិច្ច និងការរៀបចំអគ្គលេខាធិការដ្ឋាន របស់គណៈកម្មាធិការជាតិដើម្បីប្រជាជន និងការអភិវឌ្ឍន៍ **"គ.ជ.ប.អ"** ។

## ជំពូកទី២

## បេសកកម្ម តួនាទី និង ភារកិច្ច

**មាត្រា២ :** គណៈកម្មាធិការជាតិដើម្បីប្រជាជន និងការអភិវឌ្ឍន៍ មានអគ្គលេខាធិការដ្ឋានមួយ ជាអង្គភាពប្រតិបត្តិដែលត្រូវបានដឹកនាំ និងគ្រប់គ្រងដោយនាយកប្រតិបត្តិមួយរូប អមដោយនាយកប្រតិបត្តិរងពីររូប ។ នាយកប្រតិបត្តិមានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា៣ :** អគ្គលេខាធិការដ្ឋានរបស់ គណៈកម្មាធិការជាតិដើម្បីប្រជាជន និងការអភិវឌ្ឍន៍ មានបេសកកម្មអនុវត្តរាល់ការងាររបស់ **គ.ជ.ប.អ** ។ ក្នុងសកម្មភាពនេះអគ្គលេខាធិការដ្ឋានមានភារកិច្ចជាអាទិ៍ដូចខាងក្រោមនេះ ÷

- ធ្វើការសំរបសំរួលជាមួយក្រសួងពាក់ព័ន្ធនានា ភ្នាក់ងារ-អង្គការសហប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាលជាតិ និងបរទេសព្រមទាំងអង្គការមូលនិធិ និងអង្គការឯកជនពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍន៍ ។
- ធ្វើអោយដំណើរការ និងដាក់បញ្ហាប្រជាជនទៅក្នុងផែនការកម្មវិធីអភិវឌ្ឍន៍ របស់ក្រសួងពាក់ព័ន្ធក្នុងក្របខ័ណ្ឌជាតិអោយបានប្រសើរ និងមានប្រសិទ្ធភាព ។
- ធ្វើការសិក្សាអំពីដំណើរការអភិវឌ្ឍន៍ នៃការសំរេចចិត្តរបស់សន្និសីទអន្តរជាតិ ទាក់ទងនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍន៍ និងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល ។
- រៀបចំចាត់ចែងការងារ ធ្វើកំណត់ហេតុ ធ្វើរបាយការណ៍ តាមដាននិងវាយតំលៃលើគំរោងកម្មវិធីប្រជាជន និងការអភិវឌ្ឍន៍របស់ក្រសួងពាក់ព័ន្ធ សំរាប់ផែនការជាតិ ។
- ទំនាក់ទំនងជាមួយរដ្ឋសភា ស្តីអំពីច្បាប់ដែលពាក់ព័ន្ធ នឹងប្រជាជននិងការអភិវឌ្ឍន៍ ។
- បណ្តុះបណ្តាលធនធានមនុស្សតាមរយៈសិក្ខាសាលា វគ្គបណ្តុះបណ្តាលនានា ដល់បុគ្គលិកមន្ត្រីរាជការទាំងថ្នាក់ជាតិ និងថ្នាក់ខេត្ត-ក្រុង និងរៀបចំអោយមានការស្រាវជ្រាវសមស្របទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីអំពីការអភិវឌ្ឍន៍ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងរៀបចំយុទ្ធសាស្ត្រសន្តិសុខស្បៀង ។
- រៀបចំឯកសារនានាដែលពាក់ព័ន្ធ ហើយបោះពុម្ព ផលិត និងផ្សព្វផ្សាយតាមប្រព័ន្ធពត៌មាន ។
- រៀបចំ និងសំរបសំរួលសិក្ខាសាលា និងសន្និសីទ ស្តីអំពីប្រជាជន និងការអភិវឌ្ឍន៍ ។

**មាត្រា៤** : អគ្គលេខាធិការដ្ឋានរបស់ គ.ជ.ប.ស មានសិទ្ធិលើកសំណើ ពិនិត្យ និងសំរេចលើសេចក្តីប្រកាសតែងតាំងការផ្ទេរភារកិច្ច ឬ ការបញ្ឈប់ពីតំណែងនូវមន្ត្រីថ្នាក់ក្រោម របស់អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប.ស ។

## ជំពូកទី៣

## រចនាសម្ព័ន្ធ

**មាត្រា៥** : អគ្គលេខាធិការដ្ឋានរបស់ គ.ជ.ប.ស មានរចនាសម្ព័ន្ធដូចតទៅ ÷

១- ផ្នែករដ្ឋបាល និងហិរញ្ញកិច្ច

២- ផ្នែកគំរោងការ និងកម្មវិធី

**មាត្រា៦** : ការបែងចែកភារកិច្ចរបស់បុគ្គលិក និងមន្ត្រីរាជការ ដែលបំរើការងារនៅក្នុងអគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់ គ.ជ.ប.ស តាមសំណូមពររបស់នាយកប្រតិបត្តិ ។

**មាត្រា៧** : ផ្នែករដ្ឋបាល និងហិរញ្ញកិច្ច បំពេញការងាររបស់ខ្លួន គ្រប់គ្រងដោយនាយកប្រតិបត្តិរង និងអមដោយមន្ត្រីមួយចំនួនតាមការចាំបាច់ ដូចតទៅ ÷

- ទទួលខុសត្រូវផ្នែករដ្ឋបាល ចេញលិខិតស្នាម និងលិខិតអញ្ជើញ ។
- រៀបចំគំរោងថវិកា សំភារៈបរិក្ខា និងមធ្យោបាយការងារផ្សេងៗ ។
- គ្រប់គ្រងអចលនវត្ថុ ចលនវត្ថុ និងរាល់ការចំណាយផ្សេងៗ ។
- ធ្វើទំនាក់ទំនងលើបញ្ហាថវិកាជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អង្គការនានា និងស្ថាប័នដែលពាក់ព័ន្ធ ។
- លើកគំរោងចំណាយថវិកា ក្នុងការបំពេញបេសកកម្មការងារ សិក្ខាសាលា សន្និសីទ កិច្ចប្រជុំផ្សេងៗ ។ល។

**មាត្រា៨** : ផ្នែកគំរោងការ និងកម្មវិធីបំពេញការងាររបស់ខ្លួន គ្រប់គ្រងដោយនាយកប្រតិបត្តិរង និងអមដោយមន្ត្រីមួយចំនួនតាមការចាំបាច់ ដូចតទៅ ÷

- គ្រប់គ្រង និងសំរបសំរួលរាល់ការងាររបស់អ្នកសំរបសំរួលកម្មវិធី ។
- រៀបចំគំរោង និងកម្មវិធីធ្វើការងារ ។
- ទំនាក់ទំនង សហការ និងសំរបសំរួលការងារជាមួយក្រសួង អង្គការនានា និងស្ថាប័នដែលពាក់ព័ន្ធ ។
- សរុបលទ្ធផល និងលើកយោបល់សុំការសំរេចពីរាជរដ្ឋាភិបាល ។

**មាត្រា៩** អគ្គលេខាធិការដ្ឋានរបស់ គ.ជ.ម.អ អាចប្រើប្រាស់បុគ្គលិក និងមន្ត្រីរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ហើយអាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ដែលមានល័ក្ខខ័ណ្ឌការងារ និងប្រាក់បំណាច់ របស់បុគ្គលិកជាប់កិច្ចសន្យា ត្រូវកំណត់ដោយប្រកាសរបស់ **គ.ជ.ម.អ** តាមសំណើរបស់នាយកប្រតិបត្តិ ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា១០:** ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ម.អ** ចាប់ពីថ្នាក់ការិយាល័យ ក្រុម និងផ្នែក ត្រូវកំណត់ដោយប្រកាសរបស់ **គ.ជ.ម.អ** តាមសំណើរបស់នាយកប្រតិបត្តិ ។

**មាត្រា១១:** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា១២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណៈកម្មាធិការជាតិដើម្បីប្រជាជន និងការអភិវឌ្ឍន៍ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១២
- ឯកសារ-កាលប្បវត្តិ

## រចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋាន
## នៃគណៈកម្មាធិការជាតិដើម្បីប្រជាជន និងការអភិវឌ្ឍន៍

